# សាវតារវត្តរកាកណ្ដាល និងព្រះវិហារបុរាណ

វត្តរកាកណ្ដាលមានឈ្មោះមួយទៀតថាវត្តបទុមមុនីសុវណ្ណារាម ហើយទំនងជាវត្តចាស់ជាងគេក្នុងខេត្តក្រចេះ កសាងនៅប្របដងទន្លេមេគង្គលើ។ ចាប់តាំងពីកកើតវត្តមកដល់បច្ចុប្បន្ន វត្តនេះបានផ្លាស់ប្ដូរហេដ្ឋារចនាសម្ព័ន្ធដោយអន្ទើ។ ក្នុងសម័យសង្គមរាស្ត្រនិយម ព្រះសង្ឃនិងពុទ្ធបរិស័ទ បានមូលមាត់រំកិលបរិវេណវត្តថយឆ្ងាយពីច្រាំងទន្លេមកទិសខាងកើត។ បច្ចុប្បន្នផ្ទៃដីវត្តពុះចែកដោយផ្លូវជាតិមួយខ្សែ ខណ្ឌផ្នែកខាងខាលិចជាប់ផ្លូវចាស់មាត់ទន្លេ គឺជាបរិវេណសំណង់បេតិកភណ្ឌដែលមានព្រះវិហារបុរាណមួយដ៏ល្បីល្បាញ(រូបលេខ១)។[1] ផ្នែកខាងកើត គឺជាបរិវេណវត្តដែលមានព្រះវិហារថ្មី សាលាឆាន់ សាលាបាលី និងកុដិព្រះសង្ឃគង់នៅសព្វថ្ងៃ។



រូបលេខ១ ព្រះវិហារបុរាណវត្តរកាកណ្ដាល ស្ថិតក្នុងខេត្តក្រចេះ (ឆ្នាំ២០២៤)

[1] តាមប្រកាសលេខ២៦០៤ ប្រ.ក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៥ ចេញដោយក្រសួងមហាផ្ទៃ រដ្ឋបាលក្រុងក្រចេះបានគូរសំណង់ព្រះវិហារនេះកំណត់ជានិមិត្តសញ្ញាផ្លូវការសម្រាប់រដ្ឋបាលក្រុង។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

យោងតាមឯកសារសាវតារវត្តឲ្យដឹងថា វត្តរកាកណ្ដាលចាប់ផ្ដើមកសាងក្នុងព.ស. ២៣៨១(ឆ្នាំ១៨៣៨) ដោយសទ្ធារបស់បងប្អូនប្រុសពីរនាក់គឺ **ឧកញ៉ា នរេន្ទ ប៉ូច** (ជាបង) និងភរិយាឈ្មោះ **ទៀង** ព្រមទាំងប្អូនឈ្មោះ **ក្រឡាពាស ទៀង** និងភរិយាឈ្មោះ **ណិប**។ គ្រាកសាងដំបូងវត្តនេះមិនទាន់មានវិហារទេ មានតែកុដិតូចៗប្រក់ស្បូវ រហូតដល់ព.ស. ២៤០៣(ឆ្នាំ១៨៦០) ទើបកសាងព្រះវិហារប្រក់ស្បូវបញ្ចុះសីមាជារោងឧបោសថ។ នៅរវាងព.ស.២៤១៩(ឆ្នាំ១៨៧៦) ព្រះសង្ឃនិងពុទ្ធបរិស័ទបានរុះរើព្រះវិហារប្រក់ស្បូវនោះ ហើយកសាងព្រះវិហារប្រក់ក្បឿងជំនួសវិញ។ លុះដល់ព.ស.២៤៥២(ឆ្នាំ១៩០៩) ព្រះសង្ឃ និងពុទ្ធបរិស័ទបានឯកភាពរុះរើព្រះវិហារធ្វើសាឡើងជាថ្មីអំពីឥដ្ឋ និងស៊ីម៉ងត៍ (រូបលេខ២២)។[2] ប៉ុន្តែចាប់ពីក្រោយឆ្នាំ១៩៥១ ពោលគឺក្រោយរំកិលបរិវេណវត្តថយឆ្ងាយពីមាត់ទន្លេ ព្រះវិហារបុរាណនេះទំនងពុំប្រើប្រាស់បន្តទៀតឡើយ ស្របពេលព្រះវិហារថ្មីបានកសាងក្នុងដើមទសវត្សទី៦០ (រូបលេខ២៣)។



រូបលេខ២២ ព្រះវិហារបុរាណវត្តរកាកណ្ដាល ថតឆ្នាំ១៩២៩ (រូបថត៖ EFEO)



រូបលេខ២៣ ព្រះវិហារថ្មីវត្តរកាកណ្ដាល ទសវត្សទី៦០ (ប្រភព៖ កម្ពុជសុរិយា, ឆ្នាំ១៩៦៥)

ចាប់ពីសម័យសង្គ្រាមមក គេមើលឃើញថាព្រះវិហារបុរាណវត្តរកាកណ្ដាលនេះទទួលរងការខូចខាតពុកផុយយ៉ាងដំណំ (រូបលេខ២៤-៥)។ លុះមកដល់ឆ្នាំ២០០១ រដ្ឋបាលខេត្តក្រចេះ និងអង្គការសម្ព័ន្ធសិប្បកម្មកម្ពុជា បានរៀបចំជួសជុលកែលម្អឡើងវិញតាមលំនាំសិល្បៈស្ថាបត្យកម្មដើម ដោយមានជំនួយពីរដ្ឋាភិបាលប្រទេសអាល្លឺម៉ង់។ បន្ទាប់ពី

[2] ឌឹក គាម, ១៩៦៥, ទំ.៧៥-៧៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជួសជុលរួច ព្រះវិហារនេះបានប្រើប្រាស់ក្រោមឈ្មោះជា "មជ្ឈមណ្ឌលសិប្បកម្មវត្តរកាកណ្ដាល" ដាក់តាំងវត្ថុអនុស្សាវរីយ៍ និងផលិតផលសិប្បកម្មផ្សេងៗមកពីសហគមន៍ជុំវិញ។ ប៉ុន្តែការប្រើប្រាស់សម្រាប់តាំងបង្ហាញវត្ថុសិល្បៈសិប្បកម្មនេះ បានត្រឹមមួយរយៈក៏បិទទ្វារផ្អាកពុំដំណើរការឡើយ។ ក្នុងឆ្នាំ២០១០ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានចុះបញ្ជីព្រះវិហារនេះទុកជាសម្បត្តិបេតិកភណ្ឌជាតិ ព្រមទាំងបានជួសជុលនិងអភិរក្សថែទាំរហូតមកដល់បច្ចុប្បន្ន។





*រូបលេខ៤-៥ ព្រះវិហារបុរាណវត្តរកាកណ្ដាលមុនពេលជួសជុល (រូបថត៖ សម្ព័ន្ធសិប្បកម្មកម្ពុជា)*

ដោយឡែក បើមើលចំពោះការវិវឌ្ឍសិល្បៈស្ថាបត្យកម្មព្រះវិហារបុរាណខាងលើ គឺបានចាប់ផ្ដើមពីឆ្នាំ១៨៦០ ត្រឹមតែជារោងឧបោសថសង់អំពីឈើប្រក់ស្បូវ រហូតដល់ឆ្នាំ១៩០៩ បានកែលម្អមកជាសំណង់ឈើប្រក់ក្បឿងនិងជញ្ជាំងឥដ្ឋ ហើយដូចបានឃើញសព្វថ្ងៃព្រះវិហារនេះសង់នៅលើខឿន២ថ្នាក់។ ខឿនថ្នាក់ទី១ កម្ពស់ប្រហែលត្រឹមចង្កេះ ដែលផ្នែកខាងកើត និងខាងជើងមានជណ្ដើរ៣កាំ។ ផ្នែកត្បូង និងខាងលិចពុំមានជណ្ដើរឡើយ ហើយនៅជាប់ខឿនជ្រុងនិរតីមានដើមរកាធំមួយដើម។ ខឿនថ្នាក់ទី២ មានកម្ពស់ប្រហែលកន្លះម៉ែត្រ។ ចំពោះរចនាសម្ព័ន្ធជញ្ជាំងព្រះវិហារ គេមើលឃើញជាទូទៅពុំមានក្បាច់លម្អឡើយ ពោលគឺជាជញ្ជាំងឥដ្ឋកំបោរបាយអ សព្វថ្ងៃលាបពណ៌លឿងស្រាល។ ជញ្ជាំងខាងកើតនិងខាងលិចមានទ្វារម្ខាង២ អមកូនបង្អួចតូចៗ២ដូចគ្នា។ ប៉ុន្តែជញ្ជាំងខាងជើងមានទ្វារតែ១ អមដោយបង្អួចតូចៗចំនួន៥ ហើយជញ្ជាំងខាងត្បូងពុំមានទ្វារចេញចូលឡើយ មានតែបង្អួចតូចៗចំនួន៦ (រូបលេខ៦)។ ក្រោយការជួសជុល សន្ទឹកទ្វារនិងបង្អួចនីមួយៗបានរចនាលម្អដោយក្បាច់ទឹបទឹកមាសរំលេចលើផ្ទៃពណ៌ខ្មៅ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



*រូបលេខ៦ ព្រះវិហារបុរាណវត្តរកាកណ្ដាលមើលពីជ្រុងអាគ្នេយ៍ (ជញ្ជាំងខាងត្បូងគ្មានទ្វារ)*

ចំណែកឯរចនាសម្ព័ន្ធដំបូលព្រះវិហារ គឺជាប្រភេទដំបូលកិងជហ្វា៤ ប្រក់ក្បឿងស្រកាលេញជ្រាលចុះ២ថ្នាក់សងខាង ដែលគេនិយមហៅថាព្រះវិហារជហ្វា៤ឬព្រះវិហារបុរាណៗ[3] នៅរងស្បូវចុងដំបូលថ្នាក់ទី១ ពុំមានក្បាច់លម្អឡើយ តែរងស្បូវចុងដំបូលថ្នាក់ទី២ លម្អដោយក្បាច់កញ្ចាំង(?) ឆ្លាក់ពីឈើយ៉ាងរស់រវើក ព្រមទាំងដាំកញ្ចក់និងមានស្នាកស្នាមលាបទឹកមាសផង។ អ្វីដែលពិសេស នៅចំណុចកណ្ដាល និងខាងចុងនៃក្បាច់រងស្បូវមានឆ្លាក់រូបតោ(?)និងសត្វស្វាបទាំងគូ(រូបលេខ៧-៨)។ រីឯនៅចុងចែងដំបូលនីមួយៗលម្អនាគសន្ទឹក ឬនាគដងក្ដារ។ ជហ្វាទាំង៤លម្អចុងមេដំបូលនិងក្បាលនាគចែងទាំងអស់សុទ្ធតែឆ្លាក់ពីឈើយ៉ាងវិចិត្ររស់រវើក (រូបលេខ៩-១០)។



*រូបលេខ៧-៨ ចម្លាក់សត្វនិងក្បាច់លម្អលើរងស្បូវឆ្លាក់ពីឈើ*

[3] ព្រាប ចាន់ម៉ារ៉ា, ២០១៧, ទំ.១៣-២៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ៩-១០ ជហ្វា និងក្បាលនាគឆ្លាក់ពីឈើលម្អតាមចុងព្រំដំបូល និងចុងចែង

ហោជាងទាំង២នៃព្រះវិហារ ក៏សុទ្ធសឹងលម្អដោយក្បាច់ឆ្លាក់ពីឈើ។ ហោជាងមុខ និងហោជាងក្រោយឆ្លាក់រូបដូចគ្នា តែហោជាងខាងក្រោយដែលបែរទៅទន្លេ ហាក់ពុកផុយរបេះបកក្បាច់ដោយអន្ទើ។ នៅផ្នែកកណ្តាលនៃហោជាងទាំង២នេះ គេឆ្លាក់បង្ហាញរូបទេពទ្រង់មកុដគង់លើបល្ល័ង្ក ព្រះហស្ត២កាន់ព្រះខ័ននិងកងចក្រជាកេតនភណ្ឌ តែនៅលើហោជាងក្រោយប្រហែលរបេះបាត់ព្រះហស្ត២ ដែលកាន់កងចក្រ។ អមបល្ល័ង្កនោះ មានរូបហនុមាន(?)កាន់ព្រះខ័នកំពុងលើកដៃប្រណមចំពោះទេពនោះ។ រីឯផ្ទៃខាងក្រោយគេរចនាជាក្បាច់ភ្ញីភ្ញើង ហើយនៅគល់ហោជាងគេឆ្លាក់ក្បាច់ភ្ញីទេស រំលេចដោយរូបយក្ស និងមនុស្សកំពុងលើកទ្រហោជាងខាងលើ (រូបលេខ១១-១២)។

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត


រូបលេខ២១១ ក្បាច់លម្អលើហោជាងមុខ (កើត)


រូបលេខ២១២ ក្បាច់លម្អលើហោជាងក្រោយ (លិច)

ផ្នែកខាងក្នុងព្រះវិហារ បច្ចុប្បន្នឃើញមានតម្កល់ព្រះពុទ្ធបដិមា១ព្រះអង្គតូច និងគ្រឿងសក្ការបូជាផ្សេងៗនៅលើអាសនៈក្បែរជញ្ជាំងផ្នែកខាងលិច តែពុំមានព្រះជីវ៍ធំដូចព្រះវិហារដទៃឡើយ។ នៅផ្នែកកណ្ដាលព្រះវិហារមានសសរឈើមូលចំនួន២ជួរអមល្វែងគ្រឹះ និងសសរឈើមូល២ជួរទៀតជាសសររបៀង (ជាប់ជញ្ជាំង)។ សសរនីមួយៗសុទ្ធតែលម្អក្បាច់ទឹបមាស រំលេចគំនូររូបនាគព័ន្ធព័ទ្ធពីក្បាលសសរចុះមក និងក្បាច់ផ្សេងៗតាំងពីក្បាលសសរមកដល់ក្រោម។ ចំណែកគ្រឿងបង្គុំផ្នែកដំបូល សុទ្ធតែឈើទាំងអស់ហើយខ្លះដាប់ឆ្លាក់រំលេចឲ្យចេញជាក្បាច់ និងផ្នែកខ្លះទៀតលម្អដោយទឹបមាសយ៉ាងប្រណីតល្អិតល្អវិចិត្រប្លែក ពោលគឺទាំងមេដំបូល ជន្ទល់មេដំបូល ធ្នឹម ផ្តោង និងផ្ទាន គឺមានក្បាច់លម្អទាំងអស់ ដែលគួរឲ្យកោតសរសើរនូវទឹកដៃទេពកោសល្យសិល្បៈដ៏ក្រៃលែង (រូបលេខ២១៣-១៤)។



រូបលេខ២១៣-១៤ គ្រឿងបង្គុំផ្នែកដំបូល ដែលមានការលម្អដោយក្បាច់ផ្សេងៗ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

នៅផ្នែកខាងក្នុងនៃព្រះវិហារបុរាណនេះដែរ ក៏មានគំនូរសេសសល់ពីការខូចខាតខ្លះគូរនៅលើហាប់ខ្យល់ ហើយគូរជាប្រភេទគំនូរបុរាណ។ អ្នកស្រាវជ្រាវ ដានីញែល និង ដូមីនិក-ព្យែរ ហ្គេរេត៍ (Danielle & Dominique-Pierre Guéret) យល់ថាគំនូរនោះជាគំនូរពុទ្ធប្រវត្តិលាយគ្នាជាមួយឈុតឆាកខ្លះៗនៃរឿងជាតក និងរឿងរាមកេរ្តិ៍នៅផ្នែកខាងក្រោម។ អ្នកស្រាវជ្រាវទាំង២យល់ថា គំនូរនេះគឺមានតែមួយគត់ក្នុងប្រទេសកម្ពុជា។[4] ប៉ុន្តែយ៉ាងណាក្តី សព្វថ្ងៃគេឃើញមានគំនូរនៅសល់២ផ្ទាំងស្ថិតនៅលើហាប់ខ្យល់ ដែលទំនងគូរដកស្រង់ពីព្រេងកថាណាមួយក្នុងពុទ្ធប្រវត្តិ (រូបលេខ១៣-១៤) ហើយសិល្បៈគូរគំនូរបុរាណលើហាប់ខ្យល់បែបនេះ គេឃើញនៅតាមព្រះវិហារបុរាណផ្សេងទៀតដូចជា វត្តចិនដំដែក (ភ្នំពេញ), វត្តពុទ្ធា (ត្បូងឃ្មុំ), និងវត្តល្វេ (កំពង់ចាម)ជាដើម។





រូបលេខ១៥-១៦ គំនូរបុរាណលើហាប់ខ្យល់ខាងក្នុងព្រះវិហារ

4 ដានីញែល និង ដូមីនិក-ព្យែរ ហ្គេរេត៍, ២០១៧, ១២៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សង្ខេបសេចក្ដីមក ទីវត្តរកាកណ្ដាលកកើតឡើងតាំងពីចុងសតវត្សទី១៩ ហើយព្រះវិហារបុរាណដែលគង់វង្សដល់សព្វថ្ងៃកសាងឡើងក្នុងដើមសតវត្សទី២០ តែបានជួសជុលថែទាំជាបន្តបន្ទាប់ រហូតដល់បច្ចុប្បន្នមានអាយុកាល១១៦ឆ្នាំ(១៩០៩-២០២៥)។ រីឯគំនូរ និងសិល្បៈស្ថាបត្យកម្មនៃសំណង់បេតិកភណ្ឌនេះ គឺបង្ហាញពីកម្រិតទេពកោសល្យសិល្បៈដ៏ល្អវិចិត្រក្រៃលែង។ ប៉ុន្តែជាអកុសល ផ្នែកជាច្រើននៃគំនូរបានខូចខាតរលុបបាត់ដាន ដែលគួរតែមានការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីយល់ពីតម្លៃនៃសំណង់នបុរាណនេះកាន់តែស៊ីជម្រៅថែមទៀត។

## ឯកសារយោង


ដានីញ៉េល និង ដូមីនិក-ព្យែរ ហ្គេរេត៍

២០១៧, *វត្តអារាមនៅប្រទេសកម្ពុជា,* KAM edition

ឌឹក គាម

១៩៦៥, "សារតារវត្តរកាកណ្ដាល", *កម្ពុជសុរិយា,* ឆ្នាំទី៣៧, លេខ១, ទំ.៧៥-៧៧, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៧, *សំណង់នៅតាមវត្ត,* ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត